**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០១៧ ......សហវ....

# សេចក្តីជូនដំណឹង

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដល់មន្ត្រីរាជការ យោធិន កងកម្លាំងនគរបាល និងសាធារណជនទាំងអស់មេត្តាជ្រាបថា÷ ដើម្បីធានាបាននូវការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការ យោធិន និង កងកម្លាំងនគរបាលបានដល់ដៃនិងទាន់ពេលវេលានៅក្នុងសប្តាហ៍ទី៤ នៃខែនីមួយៗ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើតក្រុមការងារពិសេសមួយ សម្រាប់ទទួលព័ត៌មានរហ័សនិងទាន់ហេតុការណ៍ និងសម្រាប់ផ្តល់ព័ត៌មាននិង ជួយសម្របសម្រួលដោះស្រាយរាល់បញ្ហា ភាពអសកម្ម ភាពមិនប្រក្រតី ឬបញ្ហាប្រឈមនានា ទាក់ទងនឹងការបើក ប្រាក់បៀវត្ស ជាពិសេសការបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ។ លេខទូរស័ព្ទទំនាក់ទំនង (Hot Line) មានដូច ខាងក្រោម÷

| | |
|---|---|
| - តំណាងក្រសួងមុខងារសាធារណៈ | 012 732 377 / 099 787 797 |
| - តំណាងអគ្គនាយកដ្ឋានរតនាគារជាតិ | 012 710 037 |
| - តំណាងធនាគារ អេស៊ីលីដា ភីអិលស៊ី | 015 700 079 |
| - តំណាងធនាគារ កាណាឌីយ៉ា ក.អ | 071 333 0045 |
| - តំណាងធនាគារឯកទេសវីង (ខេមបូឌា) លីមីតធីត | 089 990 746 |

អាស្រ័យហេតុនេះ សូមមន្ត្រីរាជការ យោធិន កងកម្លាំងនគរបាល និងសាធារណជនទាំងអស់ មេត្តាជ្រាប និងសហការផ្តល់ព័ត៌មានរហ័សនិងទាន់ហេតុការណ៍ ដល់ក្រុមការងារពិសេសនេះ ដើម្បីជួយសម្របសម្រួលនិង ដោះស្រាយបញ្ហាបានទាន់ពេលវេលា។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៥*

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**


...លេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
...92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798